# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីស្ថានការណ៍សេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿនជាងគេមួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ីខាងកើត នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៤ ឆ្នាំ២០០៨ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក រួមចុះ ៦,៣% ។ ការធ្លាក់ចុះនេះបណ្តាលជាសំខាន់ពីការរួមចំនែកអវិជ្ជមាននៃ ការនាំចេញ ចំនាយប្រើប្រាស់ផ្ទាល់ខ្លួន វិនិយោគលើទ្រព្យសកម្មជាប់លាប់ និងលើគ្រឿងបរិក្ខារនិងសូហ្វវែរ ប៉ុន្តែវាមានការប៉ះប៉ូវមួយផ្នែកវិញដោយ ការរួមចំនែកវិជ្ជមាននៃចំណាយរបស់រដ្ឋាភិបាល ។ ក្នុងត្រីមាសនេះដែរ សេដ្ឋកិច្ចនៅតំបន់អឺរ៉ូ ធ្លាក់ចុះយ៉ាងខ្លាំង ដោយកំណើន ផសស ពិត ធ្លាក់ដល់ -១,៣% ហើយមូលហេតុចំបង គឺ ការថយចុះយ៉ាងខ្លាំងនូវតំរូវការទំនិញសំរាប់នាំចេញ និងការថយចុះគួរឱ្យកត់សំគាល់នៃចំណាយប្រើប្រាស់របស់វិស័យឯកជន និងរដ្ឋាភិបាល ។ ផសស ពិតនៅជប៉ុន រួមចុះ ៤,៦% ដោយសារជាសំខាន់ ការថយចុះតំរូវការនៅក្រៅប្រទេស និង ការធ្លាក់ចុះខ្លាំងនូវវិនិយោគលើរោងចក្រថ្មីៗ និងសំភារៈបរិក្ខារ ក្នុងវិស័យឯកជន ។

សម័យកាលកំណើនលេខពីរខ្ទង់របស់ប្រទេសចិន ទំនងជាឈានដល់ទីបញ្ចប់ហើយ ដោយគេសង្កេតឃើញ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ បន្តធ្លាក់ចុះមកត្រឹម ៦,៨% នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។ មូលហេតុចំបងនៃការធ្លាក់ចុះនេះ គឺ ការថយចុះផលិតផលឧស្សាហកម្មសំរាប់នាំចេញ និង ការរួមចុះវិស័យអចលនទ្រព្យ ។ នៅត្រីមាសនេះដែរ ផសស ពិត នៅកូរ៉េខាងត្បូង រួមចុះជាខ្លាំង គឺ ៣,៦% ដោយសារការធ្លាក់ចុះនៃចំណាយរបស់វិស័យឯកជន វិនិយោគលើទ្រព្យសកម្មជាប់លាប់ និងការនាំចេញទំនិញនិងសេវាកម្ម ។ ហុងកុង និង តៃវ៉ាន់ ក៏ធ្លាក់ចុះសេដ្ឋកិច្ចធ្ងន់ធ្ងរដែរ ដោយ ផសស ពិត ធ្លាក់ចុះអស់ ២,៥% និង ៨,៤% ។ ការធ្លាក់ចុះ ផសស នៅហុងកុង បណ្តាលមកពី ការធ្លាក់ចុះខ្លាំងនៃ ចំណាយប្រើប្រាស់ឯកជន (៣,២%) និង ការកាត់បន្ថយនូវការបង្កើតទ្រព្យមូលធនក្នុងស្រុកដុល (១៧,៣%) ហើយការធ្លាក់ចុះនៅតៃវ៉ាន់ បណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងនៃការនាំចេញទំនិញ និងសេវាកម្ម (១៩,៧៥%) និង ការធ្លាក់ចុះចំណាយប្រើប្រាស់ឯកជន និងការបង្កើតទ្រព្យមូលធនជាប់លាប់ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៨ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅម៉ាឡេស៊ី បន្តធ្លាក់ចុះមកត្រឹម ០,១% ។ កត្តាដែលបង្កការធ្លាក់ចុះនេះ គឺ ការរួមចុះយ៉ាងរហ័សនៃផលិតកម្ម និងការបង្កើតទ្រព្យមូលធនជាប់លាប់ដុល ។ កំនើន ផសស ពិត នៅសិង្ហបុរី ក៏ធ្លាក់ចុះដែរ ដោយសារការស្រុតចុះយ៉ាងឆាប់រហ័សនៃផលិតកម្ម ។ កំនើន ផសស ពិតនៅថៃ រួមចុះយ៉ាងខ្លាំង គឺ ៤,៣% ដោយសារ ការនាំចេញសុទ្ធធ្លាក់ចុះអស់ ៣៨,២% ហើយចំណាយវិនិយោគឯកជន ធ្លាក់ចុះអស់ ១០,២% ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០០៨ អតិផរណាថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក ធ្លាក់ចុះមកត្រឹម ១,៥% ធៀបនឹង ៥,៣% នៅត្រីមាសមុន ។ ការចុះខ្សោយនៃសំពាធអតិផរណានេះ បណ្តាលមកពីការធ្លាក់ថ្លៃខ្លាំងនៃ ប្រេង និងទំនិញប្រើប្រាស់ផ្សេងទៀត ការចុះថ្លៃជាបន្តបន្ទាប់នៃផ្ទះ និង ការបាក់ស្រុតនូវតំរូវការរបស់អ្នកប្រើប្រាស់ ។ នៅត្រីមាសនេះដែរ អតិផរណារយៈពេល ១២ខែ នៅតំបន់អឺរ៉ូ ធ្លាក់ចុះមកត្រឹម ២,៣% ធៀបនឹង ៣,៨% នៅត្រីមាសមុន ។ អតិផរណានេះ រងឥទ្ធិពលពី ថ្លៃថាមពល និង ការឡើងថ្លៃយឺតជាងមុននៃ ម្ហូបអាហារ ភេសជ្ជៈ ផ្ទះ និង សំលៀកបំពាក់ ។ ថ្លៃទំនិញប្រើប្រាស់សរុបនៅជប៉ុន កើនឡើង ១% ធៀបនឹងកំណើន ២,២% នៅត្រីមាសមុន ។

នៅត្រីមាសទី៤ ឆ្នាំ២០០៨ ដុល្លារUS នៅថេរធៀបនឹងប្រាក់យ៉ន់ចិន ប៉ុន្តែវាធ្លាក់ថ្លៃទល់នឹង ដុល្លារហុងកុង និង ប្រាក់យ៉េនជប៉ុន ដោយប្តូរបាន ៧,៧៥ដុល្លារហុងកុង/ដុល្លារUS និង ៩៦,១យ៉េន/ដុល្លារUS ។ ដុល្លារUS ឡើងថ្លៃទល់នឹង ប្រាក់អឺរ៉ូ ប្រាក់វ៉ុនកូរ៉េខាងត្បូង និង ដុល្លារតៃវ៉ាន់ ដោយប្តូរបាន ១,៣២អឺរ៉ូ/ដុល្លារUS ១៣៦៧,២វ៉ុន/ដុល្លារUS និង ៣៣,០ដុល្លារតៃវ៉ាន់/ដុល្លារUS ។ ការឡើងថ្លៃប្រាក់ដុល្លារUS អាចធ្វើឱ្យស្ថានភាពប្រកួតប្រជែងរបស់ប្រទេសចុះខ្សោយ ដោយសារការនាំចេញមានតំលៃថ្លៃជាងមុន ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

ដោយសារសេដ្ឋកិច្ចពិភពលោកនៅតែបន្តធ្លាក់កំណើន វិស័យកសិកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទំនងជាមានស្ថានភាពមិនល្អទេ នៅក្នុងរយៈពេលខ្លី ។ នៅត្រីមាសទី៤ ឆ្នាំ២០០៨ ផលិតផលកសិកម្មចំបងៗបាន ធ្លាក់ថ្លៃគួរឱ្យកត់សំគាល់ ។ បើធៀបនឹងត្រីមាសមុន ពោត (US លេខ២) ធ្លាក់ថ្លៃអស់ ២៨,៩%, ប្រេងឆា (នៅអឺរ៉ុបខាងពាយព្យ) ធ្លាក់ថ្លៃអស់ ៤០,៥%, អង្ករ (Thai 100% B) អស់ ២១,០% និង សណ្តែកសៀង (US លេខ១) អស់ ២៧,៧% ។ នៅត្រីមាសនេះដែរ ប្រេងឆៅ សាំង និង ម៉ាស៊ូត សុទ្ធតែធ្លាក់ថ្លៃ ដោយប្រេងឆៅ លក់ថ្លៃ ៥៥,២២ដុល្លារUS/ធុង, សាំង លក់ថ្លៃ ៣៤,៥២សេន/លីត្រ និង ម៉ាស៊ូត ៤៦,៥៨សេន/លីត្រ ៕

*រៀបរៀងដោយ*
*សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-០៨ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7 | 7.7 | 13.4 | 10.6 | 10.2 | 13.6 | - | - | - | - |
| ឥណ្ឌូនេស៊ី | 4.9 | 5.1 | 5.6 | 5.4 | 6.3 | 6.5 | 6.3 | 6.4 | 6.1 | 5.2 |
| ម៉ាឡេស៊ី | 5.4 | 7 | 5.2 | 5.9 | 6.3 | 7.3 | 7.1 | 6.3 | 4.7 | 0.1 |
| សិង្ហបុរី | 1.4 | 8.5 | 5.7 | 7.7 | 7.7 | 6.0 | 7.2 | 1.9 | -0.6 | -4.2 |
| ថៃ | 6.9 | 6 | 4.5 | 4.8 | 4.9 | 5.7 | 6.0 | 5.3 | 3.9 | -4.3 |
| វៀតណាម | 7 | 7.5 | 8.4 | 8.1 | 8.5 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.9 | 9.5 | 9.6 | 10.5 | 11.9 | 11.2 | 10.6 | 10.1 | 9.0 | 6.8 |
| ហុងកុង | 3.2 | 8.3 | 6.5 | 6.6 | 6.4 | 6.7 | 6.8 | 4.2 | 1.7 | -2.5 |
| កូរ៉េខាងត្បូង | 3 | 4.7 | 4.7 | 5.0 | 4.9 | 5.7 | 5.7 | 4.8 | 3.8 | -3.6 |
| តៃវ៉ាន់ | 3.1 | 5.7 | 4.1 | 4.6 | 5.2 | 6.4 | 6.4 | 4.3 | -1.0 | -8.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.5 | 1.8 | 1.5 | 2.7 | 2.9 | 2.2 | 2.2 | 1.4 | 0.6 | -1.3 |
| ជប៉ុន | 2.6 | 3.4 | 2.5 | 2.1 | 2.0 | 2.0 | 1.3 | 1.0 | -0.5 | -4.6 |
| សហរដ្ឋអាមេរិក | 3.1 | 4.4 | 3.7 | 3.3 | 2.2 | 2.5 | 2.5 | 2.8 | -0.5 | -6.3 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.2 | 4.0 | 5.8 | 4.7 | 10.5 | 9.6 | 16.5 | 24.9 | 21.7 | 15.7 |
| ឥណ្ឌូនេស៊ី | 8.3 | 8.3 | 10.5 | 13.4 | 6.4 | 6.7 | 7.6 | 10.1 | 11.9 | 11.4 |
| ម៉ាឡេស៊ី | 1.1 | 1.6 | 3.1 | 3.7 | 2.0 | 2.2 | 2.6 | 4.8 | 8.4 | 5.9 |
| សិង្ហបុរី | 0.5 | 1.7 | 0.5 | 1.0 | 2.1 | 4.1 | 6.6 | 7.5 | 6.5 | 5.5 |
| ថៃ | 1.8 | 2.7 | 4.5 | 4.7 | 2.2 | 2.9 | 5.0 | 7.7 | 7.2 | 2.2 |
| វៀតណាម | 3.1 | 7.8 | 8.2 | 7.7 | 8.3 | 10.7 | 16.4 | 24.4 | 29.0 | 23.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 1.2 | 3.9 | 1.8 | 1.5 | 4.8 | 6.6 | 8.0 | 7.8 | 5.3 | 2.5 |
| ហុងកុង | -2.6 | -0.4 | 1.1 | 2.2 | 2.0 | 3.5 | 4.6 | 5.7 | 4.6 | 2.3 |
| កូរ៉េខាងត្បូង | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 3.3 | 3.7 | 4.8 | 5.5 | 4.5 |
| តៃវ៉ាន់ | -0.3 | 1.6 | 2.3 | 0.6 | 1.8 | 4.5 | 2.3 | 4.2 | 4.5 | 1.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 2.9 | 3.4 | 3.8 | 3.8 | 2.3 |
| ជប៉ុន | -0.3 | Nil | -0.3 | 0.5 | 0.1 | 0.5 | 1.0 | 1.4 | 2.2 | 1.0 |
| សហរដ្ឋអាមេរិក | 2.3 | 2.7 | 3.4 | 3.2 | 2.9 | 3.9 | 4.1 | 4.4 | 5.3 | 1.5 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3973 | 4016.3 | 4092.5 | 4103.2 | 4062.7 | 4026 | 3995.3 | 4030.3 | 4117.4 | 4089.8 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8577 | 8938 | 9705 | 9134 | 9419 | 9246.3 | 9248.2 | 9265.3 | 9216.3 | 11,060 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.79 | 3.67 | 3.31 | 3.35 | 3.22 | 3.21 | 3.37 | 3.56 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.74 | 1.69 | 1.66 | 1.59 | 1.51 | 1.45 | 1.41 | 1.37 | 1.43 | 1.49 |
| ថៃ (បាត) | 41.5 | 40.2 | 40.2 | 37.9 | 32.22 | 33.87 | 32.37 | 32.25 | 34.0 | 34.83 |
| វៀតណាម (ដុង) | 15,510 | 15,777 | 15,859 | 15,994 | 16,030 | 16,084 | 15,896 | 16,881 | 16,517 | 16,537 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.19 | 7.97 | 8.03 | 7.43 | 7.16 | 6.96 | 6.82 | 6.83 |
| ហុងកុង (ដុល្លារហុងកុង) | 7.78 | 7.79 | 7.78 | 7.77 | 7.8 | 7.77 | 7.79 | 7.80 | 7.77 | 7.75 |
| កូរ៉េខាងត្បូង (វ៉ុន) | 1192 | 1145 | 1024 | 955 | 929.04 | 921.23 | 955.89 | 1018.84 | 1207.0 | 1,367.2 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 34.4 | 33.6 | 32.1 | 32.5 | 32.85 | 32.4 | 31.52 | 30.45 | 31.20 | 33 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.89 | 0.80 | 0.80 | 0.80 | 0.7 | 0.69 | 0.7 | 0.64 | 0.71 | 1.32 |
| ជប៉ុន (យ៉េន) | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 113.07 | 105.2 | 104.53 | 104.03 | 96.1 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៣-២០០៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - US ($/តោន) | 95.42 | 110.65 | 89.19 | 111.04 | 149.08 | 156.9 | 198.39 | 238.03 | 254.99 | 181.22 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 402.03 | 427.47 | 381.32 | 433.85 | 707.68 | 841.39 | 1048.49 | 1086.89 | 949.03 | 564.50 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 182.22 | 221.67 | 262.88 | 282.00 | 305.36 | 323.92 | 444.43 | 839.58 | 657.88 | 519.41 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 218.86 | 262.03 | 224.25 | 213.88 | 294.59 | 366.59 | 449.64 | 479.97 | 529.30 | 382.72 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.8 | 33.5 | 50.14 | 61.58 | 69.25 | 82.88 | 93.77 | 117.48 | 115.30 | 55.23 |
| សាំង - US Gulf Coast (សេន/លីត្រ) | 23 | 30.9 | 42.19 | 47.70 | 53.58 | 59.48 | 64.21 | 80.90 | 81.27 | 34.52 |
| មាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 21.63 | 29.48 | 44.35 | 51.35 | 55.51 | 66.54 | 73.99 | 95.37 | 88.46 | 46.98 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី ៤ ឆ្នាំ២០០៨ អនុមតិគម្រោងវិនិយោគសរុប ថយចុះ ៦៥% មកត្រឹម ១.៥៨០,៣លានដុល្លារ ។ ធៀបនឹងត្រីមាសមុន អនុមតិគម្រោងក្នុងវិស័យកសិកម្ម ធ្លាក់ចុះ ៧៦% មកត្រឹម ៤,៤លានដុល្លារ ចំណែកឯក្នុងវិស័យសេវាកម្ម ក៏ថយចុះ ៧០%មកត្រឹម ១.៣៣៩,៦លានដុល្លារ ។ អនុមតិគម្រោងក្នុងវិស័យឧស្សាហកម្ម កើនឡើង មួយជាបួន ដល់ ៤៨៥,៤លានដុល្លារ ដោយសារជាសំខាន់ អនុមតិគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីស្ទឹងអាតៃ នៅខេត្តពោធិ៍សាត់ ដែលមានតម្លៃដល់ ៤០៨,៣លានដុល្លារ បើទោះបីជាអនុមតិគម្រោងក្នុងវិស័យកាត់ដេរ ធ្លាក់ចុះមកត្រឹម ២១,៤លានដុល្លារក្ដី ។ ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានឱ្យដឹងថា ការធ្លាក់ចុះក្នុងអនុវិស័យកាត់ដេរ បណ្ដាលឡើងមួយផ្នែកមកពីការធ្លាក់ចុះកំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក ដែលជាទីផ្សារសំរាប់ការលក់ចេញប្រហែលជិត ៧០%នៃផលិតផលកាត់ដេររបស់កម្ពុជា ។ ក្នុងអនុមតិគម្រោងសេវាកម្មសរុប គម្រោងខាងទេសចរណ៍ មាន ៦៣% និងសណ្ឋាគារ ២៤% និងមានគម្រោងមួយចំនួនតូចទៀតសំរាប់ ការតំឡើងប្រព័ន្ធទូរគមនាគមន៍ និងសេវាសាងសង់ ។ អនុមតិគម្រោងគិតជាទ្រព្យសកម្មជាប់លាប់ខាងទេសចរណ៍ មួយភាគធំជាគម្រោងអភិវឌ្ឍកោះនៅខេត្តព្រះសីហនុ និងកោះកុង ដែលភាគច្រើនជាវិនិយោគរបស់ប្រជាពលរដ្ឋកម្ពុជា ។ គម្រោងវិនិយោគ បើអនុវត្តបានទាំងអស់ អាចផ្ដល់រហូតដល់ ៣២.៣៨០ការងារ ក្នុងនេះ វិស័យឧស្សាហកម្មមាន ១៥.៤៥៦ការងារ វិស័យសេវាកម្ម មាន ១៥.៦៦៦ការងារ និងវិស័យកសិកម្ម មាន ១.២៥៨ការងារ ។

នៅរាជធានីភ្នំពេញ គម្រោងសាងសង់ចំនួន ៨៧ ដែលមានតម្លៃ ៣៥១,៩លានដុល្លារ ត្រូវបានអនុម័ត នៅត្រីមាសទី៤ ឆ្នាំ២០០៨ ក្នុងនេះសំរាប់ប្រភេទផ្ទះល្វែង មាន ៣៨គម្រោង (៩៤៧ផ្ទះល្វែង) តម្លៃ ៦០លានដុល្លារ និងសំរាប់ភូមិគ្រឹះនិងផ្ទះ មាន ២៨គម្រោង តម្លៃ ៣៩,៧លានដុល្លារ ។ ធៀបនឹងត្រីមាសមុន តម្លៃសរុបនៃ អនុមតិគម្រោងសាងសង់ ធ្លាក់ចុះ ២៨% ក្នុងនេះ ខាងសំណង់ផ្ទះល្វែង ធ្លាក់ចុះ ៨,៥% រីឯខាងភូមិគ្រឹះនិងផ្ទះ ធ្លាក់ចុះ ២៤% ។ ទោះយ៉ាងនេះក្ដី អនុមតិគម្រោងសាងសង់សរុប កើនឡើង ១០៤% ធៀបនឹងត្រីមាសដូចគ្នា ក្នុងឆ្នាំ២០០៧ ក្នុងនេះ សំណង់ផ្ទះល្វែង កើន ៤,២% ហើយសំណង់ភូមិគ្រឹះនិងផ្ទះ កើនយ៉ាងខ្លាំង ដល់ ៩៧% ។

នៅត្រីមាសទី ៤ ការនាំចេញសរុប ធ្លាក់ចុះ ២២% រីឯការនាំចូលសរុប ថយចុះ ១១% បើធៀបនឹងត្រីមាសមុន ។ ដូច្នេះ ឱនភាពពាណិជ្ជកម្ម មានស្ថានភាពកាន់តែធ្ងន់ធ្ងរឡើងដោយកើនដល់ ១៨៧,៧លានដុល្លារ ធៀបនឹង ៩៨,៤លានដុល្លារនៅត្រីមាសមុន ។ ការស្រុតចុះនៃការនាំចេញ បណ្ដាលមកពីការនាំចេញសំលៀកបំពាក់ធ្លាក់ចុះយ៉ាងខ្លាំងអស់ ៥៦% មកត្រឹម ៦៧៨,៨លានដុល្លារ និងការនាំចេញកៅស៊ូដែលថយចុះ ៥៥% មកត្រឹម ៥,២លានដុល្លារ ។ ការនាំចេញត្រី ពុំមានការប្រែប្រួលទេ ។

ការនាំចូលសរុបបានធ្លាក់ចុះ ដោយសារការនាំចូលផលិតផលប្រេងកាត ថយចុះ ៧,៨% មកត្រឹម ៦២,៩លានដុល្លារ និង សម្ភារៈសំណង់ ថយចុះ ១៦% មកត្រឹម ២៩,៩លានដុល្លារ ក្នុងនេះ ស៊ីម៉ងត៍ ធ្លាក់ចុះ ៧,៨% មកត្រឹម ១០,៥លានដុល្លារ ដែកថែប ធ្លាក់ចុះ ៤,៥% មកត្រឹម ៩,៨លានដុល្លារ និង បរិក្ខារសំណង់ ធ្លាក់ចុះ ៣១% មកត្រឹម ៩,៦លានដុល្លារ ។ ការនាំចូលបារី ធ្លាក់ចុះ ១៤% មកត្រឹម ៣២,៨លានដុល្លារ និងយានយន្ត (រួមទាំងគ្រឿងបន្លាស់) ថយចុះ ១៥% មកត្រឹម ៨៤,៣លានដុល្លារ ។ ចំណែកឯការនាំចូលគ្រឿងស្លៀកពាក់ រួមមានសំលៀកបំពាក់ និងក្រណាត់ កើនឡើង ១២% ដល់ ១៤,៩លានដុល្លារ ។

បន្ទាប់ពីបានធ្លាក់ចុះអស់ ២ត្រីមាសកន្លងមក ចំនួនភ្ញៀវមកដល់កម្ពុជា បានកើនឡើងវិញ ។ នៅត្រីមាសទី៤ ឆ្នាំ២០០៨ ភ្ញៀវមកដល់សរុប មាន ៥៧៧.៥៣៦នាក់ ឬ កើន ៣០% ធៀបនឹងត្រីមាសមុន ។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ២២% ដល់ ៣១៦.១៦៩នាក់ ដែលក្នុងនោះ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបាន ៤៦% និង អាកាសយានដ្ឋានសៀមរាប ទទួលបាន ៥៤% ។ ភ្ញៀវមកដល់តាមផ្លូវគោក មាន ២៤២.០៥៣នាក់ ឬ កើន ៤១% រីឯភ្ញៀវមកដល់តាមផ្លូវទឹក មាន ១៩.៣១៤នាក់ ឬកើន ៣៦% ។ ភ្ញៀវមកសំរាកលំហែ កើន ១៨% ដល់ ៤៦២.៣៩៩នាក់ ប៉ុន្តែភ្ញៀវមកធ្វើជំនួញ ធ្លាក់ចុះ ០,៤% ។ កូរ៉េខាងត្បូង ជាប្រទេសនាំមុខគេខាងភ្ញៀវធ្វើដំណើរមកកម្ពុជា (៥០.០៩៤នាក់) ហើយបន្ទាប់មក គឺ វៀតណាម (៤៩.៣៨៥នាក់) និង ជប៉ុន (៤២.៨៣៦នាក់) ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០០៨ ថវិការដ្ឋមានអតិរេក ប៉ុន្តែតពីនោះមក តុល្យភាពថវិកាកាន់តែយ៉ាប់យ៉ឺនឡើងអស់ពេញមួយឆ្នាំ ។ នៅត្រីមាសទី៤ ឱនភាពសរុប មាន ៤៩៥,៩ពាន់លានរៀល ធៀបនឹង ៣៦៥,៨ពាន់លានរៀល នៅត្រីមាសមុន ។ ការប្រមូលប្រាក់ចំណូល និងការចំណាយ បានកើនឡើងដូចគ្នា ។ ការប្រមូលប្រាក់ចំណូល កើន ៣% ដល់ ១៣៣៥,៣ពាន់លានរៀល ក្នុងនោះ ចំណូលពន្ធកើន ៣,២% ដល់ ១១០៥,៧ពាន់លានរៀល ។ ពន្ធក្នុងស្រុកប្រមូលបាន ៧៩៦,៣ពាន់លានរៀល ក្នុងនោះ ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ និង ពន្ធលើតំលៃលើស មាន ១៤៦,៣ពាន់លានរៀល ឬកើន ១១% ។ អាករពិសេសលើទំនិញ កើន ៥,២% ដល់ ២១៨,០ពាន់លានរៀល និង អាករពិសេសលើសេវា កើន ១,៤% ដល់ ៣៤,១ពាន់លានរៀល ចំណែកឯពន្ធទូទៅលើទំនិញនិងសេវា ធ្លាក់ចុះ ១,៤% មកដល់ ៣៩១,០ពាន់លានរៀល ។ ក្នុងការប្រមូលពន្ធទូទៅ ពន្ធលើតម្លៃបន្ថែម មាន ៣៨៦,១ពាន់លានរៀល ឬ ថយចុះ ១,៦% ។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិ កើន ៥,១% ដល់ ៣០៩,៤ពាន់លានរៀល ដែលក្នុងនោះ ពន្ធលើការនាំចូល កើន ១៤% ដល់ ២៩៤,៧ពាន់លានរៀល ប៉ុន្តែពន្ធលើការនាំចេញ ធ្លាក់ចុះ ៥៩% មកត្រឹម ១៤,៨ពាន់លានរៀល ។ ចំណូលមិនមែនពន្ធ ធ្លាក់ចុះ ១៧% មកត្រឹម ៣០៩,៤ពាន់លានរៀល ដែលក្នុងនោះ ប្រាក់ចំណូលពីការជួលដីធ្លី និងសហគ្រាសសាធារណៈ ធ្លាក់ចុះ ៧,៦% មកត្រឹម ១០,២ពាន់លានរៀល ។ ចំណូលពីការលក់ទំនិញ និងសេវា រួមទាំងកំរៃរដ្ឋបាល និងចំណូលពីការជួលទ្រព្យវិនិយោគ កើន ១០% ដល់ ១០៩,៨ពាន់លានរៀល ។ ចំណូលមូលធន កើនលើសពីមួយជាបួន រហូតដល់ ៤៩,៣ពាន់លានរៀល ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅត្រីមាសទី៤ ចំណាយសរុប មាន ១៨៣១,២ពាន់លានរៀល ឬកើន ១០% ធៀបនឹងត្រីមាសមុន ។ ជាទូទៅ ចំណាយលើប្រាក់បៀវត្សរ៍ ដែលតាមធម្មតាមានច្រើនបំផុតនៅត្រីមាសទី៤នៃឆ្នាំនីមួយៗ មានចំនួន ៤១៥,៧ពាន់លានរៀល ឬ កើន ១៤% ធៀបនឹងត្រីមាសមុន ។ ឧបត្ថម្ភធនខាងសង្គមកិច្ច និងអំណោយផ្សេងៗ កើនច្រើនជាងមួយជាពីរ ដល់ ៣៨៥,២ពាន់លានរៀល ។ ចំណាយមូលធន កើន ៣៦% ដល់ ៨៧៤,០ពាន់លានរៀល ដោយសាររដ្ឋាភិបាលបង្កើនចំណាយលើការទិញទ្រព្យរូបី និងដីធ្លី ។ ក្នុងចំណាយមូលធនសរុប មាន ១៩% ទទួលបានហិរញ្ញប្បទានពីប្រភពទុនក្នុងស្រុក និង ៨១%ទៀតពីប្រភពទុនក្រៅប្រទេស ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ មានកំរិត ១៥,៨% ធៀបនឹង ២១,៧% នៅត្រីមាសមុន ។ ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ឡើងថ្លៃ ២៦,១% ។ ការថែទាំសុខភាព ឡើងថ្លៃ ១០,៨% តែចុះទាបជាងត្រីមាសមុន ២,២% ។ អតិផរណាថ្លៃទឹកភ្លើងរបស់គ្រួសារ មានអត្រា ៦,៧% រីទាបជាងត្រីមាសមុន ១,២% ។ ចំណាយប្រចាំថ្ងៃរបស់គ្រួសារ មានអត្រាអតិផរណា ២៦% រីទាបជាងត្រីមាសមុន ១,៤% ។ អត្រាអតិផរណាសំរាប់ការដឹកជញ្ជូន និងទូរគមនាគមន៍ គឺ ៨,០% ធៀបនឹង ២៥,៤%នៅត្រីមាសមុន ។ ក្រសួងផែនការបានឱ្យដឹងថា អតិផរណាបានធ្លាក់ចុះ ដោយសារប្រេងកាតចុះថ្លៃ ហើយការប្រមូលផលកសិកម្ម និងការនេសាទត្រី បានលទ្ធផលល្អ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៨ ប្រាក់រៀលឡើងថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារUS បើធៀបនឹងត្រីមាសមុន ដោយប្តូរបាន ៤០៨៩,៨រៀល/ដុល្លារUS ប៉ុន្តែបានធ្លាក់ថ្លៃ ១,៥% បើធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៧ ។ ប្រាក់រៀលឡើងថ្លៃ ៣,៤% និង ១,៨% ទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ដោយប្តូរបាន ១១៧,៧រៀល/បាត និង ២៤,៣រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅខែធ្នូ ២០០៨ ទ្រព្យសកម្មបរទេសសុទ្ធ មាន ១០.៣៤៥,៦ពាន់លានរៀល ឬ ធ្លាក់ចុះ ៣,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ឥណទានក្នុងស្រុក កើនដល់ ៦៩០៧,១ពាន់លានរៀល ដែលក្នុងនោះ បំណុលរបស់រដ្ឋាភិបាល ធ្លាក់ចុះ ៨,៩% មកត្រឹម ២៧០,៥ពាន់លានរៀល ។ ប្រាក់បញ្ញើរដ្ឋាភិបាល កើនដល់ ៣២៥៧,៥ពាន់លានរៀល ចំណែកឯ ឥណទានដល់វិស័យឯកជន កើន ៥៥% ដល់ ៩៨៩៤,១ពាន់លានរៀល ។

រូបិយវត្ថុទូទៅ (M2) កើនដល់ ១១.៨៥៨,៩ពាន់លានរៀល ធៀបនឹង ១១.៣១០,៧ពាន់លានរៀល នៅខែដូចគ្នា ឆ្នាំមុន ។ ប្រាក់រៀលចរាចរ កើន ១៥% ដល់ ២២៩៤,៨ពាន់លានរៀល ហើយ ប្រាក់បញ្ញើជារៀល កើន ៥៨% ដល់ ២៨៩,៦ពាន់លានរៀល ។ ប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើនតិចតួចដល់ត្រឹម ៩២៧៤,៥ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

នៅខែកុម្ភៈ ២០០៩ ក្នុងចំណោមជនងាយរងគ្រោះទាំង ១០ក្រុម មាន ៧ក្រុមមានប្រាក់ចំណូលប្រចាំថ្ងៃពិត ធ្លាក់ចុះ ធៀបនឹងខែវិច្ឆិកា ២០០៨ ។ តាមរយៈលទ្ធផលអង្កេត ក្រុមអ្នកឆ្លើយសម្ភាសន៍នានាយល់ឃើញថា ការធ្លាក់ចុះប្រាក់ចំណូលប្រចាំថ្ងៃពិត បណ្តាលឡើងមួយផ្នែកមកពី វិបត្តិសេដ្ឋកិច្ចសាកល ។

នៅខែកុម្ភៈ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ ថយចុះ ៣៤% មកត្រឹម ៨៣៦៦រៀល ធៀបនឹង ១២.៦២៨រៀលនៅខែវិច្ឆិកា ២០០៨ ។ ក្នុងចំនោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ មាន៥០% បាននិយាយថា ប្រាក់ចំណូលរបស់ពួកគាត់ធ្លាក់ចុះ ដោយសារចំនួនអ្នកធាក់ស៊ីក្លូកើនឡើង ។ ពួកគាត់ភាគច្រើននិយាយថា ប្រាក់ចំណូលរបស់គាត់ មិនទៀងទាត់ឡើយ ហើយបានត្រឹមតែសំរាប់ចិញ្ចឹមជីវិតពីមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ ។ម្យ៉ាងទៀត មាន ៨២% បញ្ជាក់ថា ពួកគាត់ត្រូវបង់ថ្លៃជួលស៊ីក្លូពី ២០០០ ទៅ ២៥០០រៀលក្នុងមួយថ្ងៃ ទោះបីជាថ្ងៃខ្លះ ពួកគាត់រកប្រាក់សឹងតែមិនបានសោះក្តី ។

ក្នុងចំណោមអ្នករត់ម៉ូតូឌុបដែលឆ្លើយសម្ភាសន៍ មាន ៧៥%មកពីខេត្តផ្សេងៗ ហើយ ៦០% ស្នាក់នៅតាមផ្ទះជួល ។ ពួកគាត់រាយការណ៍ថា ប្រាក់ចំណូលបានធ្លាក់ចុះ ២៧% ធៀបនឹងខែវិច្ឆិកា ២០០៨ ហើយមាន ៧៧,៥% និយាយថា ពួកគាត់មិនអាចសន្សំលុយបានទេ ដោយសារប្រាក់ចំណូលបានធ្លាក់ចុះ ។ ពួកគាត់ត្អូញត្អែរថា ថ្មីៗនេះ មានពេលខ្លះពួកគាត់ស្ទើរតែរកប្រាក់ទិញអាហារមិនបានផង ។

នៅខែកុម្ភៈ ប្រាក់ចំណូលរបស់កម្មករសំណង់មានជំនាញ ថយចុះ ៩% ធៀបនឹងខែវិច្ឆិកា ឆ្នាំមុន ។ ក្នុងចំនោមកម្មករសំណង់មានជំនាញដែលផ្តល់បទសម្ភាសន៍ មាន ៣២,៥% បញ្ជាក់ថា ការធ្លាក់ចុះនេះបណ្តាលមកពីការធ្លាក់ចុះជាបណ្តោះអាសន្ននៃគម្រោងសាងសង់ និងមាន ៦០% ប្រាប់ថា មានការកាត់បន្ថយចំនួនកម្មករនៅការដ្ឋានមួយចំនួន ដោយសារមានគម្រោងសាងសង់តិច ។ ប្រាក់ចំណូលរបស់ កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៣២% មកត្រឹម ៥៩៥៥រៀល/ថ្ងៃ ធៀបនឹងកាលពីខែវិច្ឆិកា ដោយសារការងារមានមិនទៀងទាត់ គឺពេលខ្លះ គ្មានការងារធ្វើ ឬមានការងារធ្វើមិនពេញមួយថ្ងៃ ។ ម្យ៉ាងទៀត មានកម្មករ ៦២,៥% និយាយថា ចំនួនកម្មករគ្មានជំនាញដែលស្វែងរកការងារសំណង់បានកើនឡើង នៅអំឡុងពេលនេះ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មកររោងចក្រកាត់ដេរ ស្ទើរតែគ្មានការផ្លាស់ប្តូរចាប់ពីខែវិច្ឆិកាមក ។ ក្នុងចំណោមកម្មករដែលឆ្លើយសម្ភាសន៍ មាន ៤៩% និយាយថា នៅដើមឆ្នាំ២០០៩ មិនមានការងារបន្ថែមម៉ោងសំរាប់ពួកគេឡើយ ហើយ ៣៦%ទៀតនិយាយថា មានការងារបន្ថែមម៉ោងដែរតែមិនសូវញឹកញាប់ ប៉ុន្តែមាន ១៥% ប្រាប់ថា មានការងារបន្ថែមម៉ោងធ្វើជាទៀងទាត់ ។ កម្មករត្អូញត្អែរថា ការងារបន្ថែមម៉ោងបានកាត់បន្ថយ ហើយចំនួនកម្មករក៏បានកាត់បន្ថយទៀត ដោយសាររោងចក្រកាត់ដេរមួយចំនួនបិទទ្វារ (ក្នុងសំណាករោងចក្រចំនួន ១០ នៃអង្កេត មាន ២រោងចក្របានបិទទ្វារ ) ។ ពួកគាត់បន្ថែមថា នឹងមានការបាត់បង់ការងារកាន់តែ

ច្រើនទៀត ប្រសិនបើការបញ្ជាទិញពីបរទេសនៅតែបន្តធ្លាក់ចុះ ព្រោះវាធ្វើឱ្យរោងចក្រកាន់តែច្រើនត្រូវបិទទ្វារ ។ នេះជាក្តីបារម្ភមួយធំសំរាប់អនាគតរបស់ពួកគាត់ ពីព្រោះពិបាកស្វែងរកការងារផ្សេងទៀតណាស់ ។

នៅខែកុម្ភៈ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់ដូរតូចតាច ធ្លាក់មកត្រឹម ៧៤៦៤រៀល ធៀបនឹង ៩៨៩៧រៀលកាលពីខែវិច្ឆិកា ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៨០% រាយការណ៍ថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគាត់ធ្លាក់ចុះ ស្របពេលដែលចំនួនអ្នកលក់ដូរតូចតាចកើនឡើង និងមាន ៥០% ទៀតនិយាយថា ពួកគាត់បានខ្ចីលុយពីអ្នកចងការប្រាក់ដើម្បីដំណើរការមុខរបររបស់ខ្លួន ។

នៅខែកុម្ភៈ ២០០៩ អ្នករើសអេតចាយរកចំណូលបានច្រើនជាងកាលពីខែវិច្ឆិកា ២០០៨ ដោយប្រាក់ចំណូលរបស់ពួកគាត់ កើនឡើង ៩% ដល់ ៥០៦៨រៀល/ថ្ងៃ ។ អ្នកឆ្លើយសម្ភាសន៍ ៧៣% បានរាយការណ៍ថា កំណើននេះបានមកពីបរិមាណរបស់អេតចាយកើនឡើង ។ អ្នកឆ្លើយសម្ភាស ៦៤% ជាអ្នកមកពីជនបទជាមួយនឹង ក្រុមគ្រួសារទាំងមូលតែម្តង ក្នុងនេះមានគ្រួសារ ៣៥% គ្មានដីធ្លីទេ ៥៣% មានដីកសិកម្មត្រឹម ១ហិកតា រឺតិចជាង ហើយ ១២%ទៀត មានដីលើសពី ១ហិកតា ។

ប្រាក់ចំណូលរបស់អ្នកលីសែង កើន ១៤% ដល់ ១០.២៧០រៀល/ថ្ងៃ នៅខែកុម្ភៈ ធៀបនឹងត្រឹម ៩០០៤រៀល/ថ្ងៃ កាលពីខែវិច្ឆិកា ។ អ្នកលីសែងភាគច្រើន និយាយថា ពួកគាត់នៅតែមិនអាចសន្សំលុយ សំរាប់គ្រួសារបានដដែល ព្រោះការចំណាយលើម្ហូបអាហារក៏កើនឡើងដែរ ដល់ ៧០០០រៀល/ថ្ងៃ ៕

*រៀបចំដោយ*
*ប៊ុន ដូរីណា និង ផាន់ ដាលីស*

# Cambodia Development Review—2009 Subscription Rates

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000 riels) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed...........................................................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000 riels for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed...........................................................................

**International Subscription (Individual)**

| | | |
|---|---|---|
| ❐ Thailand, Laos, Vietnam | ❐ English edition ($25)* | ❐ Khmer edition ($15)* |
| ❐ Asia and Europe | ❐ English edition ($30)* | ❐ Khmer edition ($20)* |
| ❐ Americas and Africa | ❐ English edition ($35)* | ❐ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❐Mr ❐Ms ❐Dr ❐Other ...........................................................................

First name: ..................................................... Last name: ........................................................ Position: .........................................................

Organisation / Company: ...........................................................................

Address (CCC Box if applicable): ...........................................................................

City / Province: ..................................................................................... Country: ...........................................................................

Telephone: ..................................................................................... Fax: ...........................................................................

e-mail: ..................................................................................... ❐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 19.1 | 2.1 | 12.0 | 102.4 | 52.3 | 16.7 | 18.6 | 4.4 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 142.7 | 51.2 | 187.2 | 328.0 | 52.9 | 95.0 | 91.6 | 485.4 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *36.6* | *24.3* | *40.7* | *69.1* | *42.3* | *47.8* | *31.3* | *21.4* |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 335.7 | 138.0 | 957.7 | 311.1 | 148.2 | 4064.9 | 4450.5 | 1339.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *140.3* | *55.0* | *653.8* | *199.2* | *93.7* | *4015.0* | *3481.3* | *1168.1* |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 497.5 | 191.3 | 1156.9 | 741.5 | 253.4 | 4176.5 | 4560.7 | 1580.3 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | -48.8 | -61.6 | 504.7 | -35.9 | -78.1 | 1548.2 | 9.2 | -65.3 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | 118.9 | 91.8 | 334.6 | -23.7 | -49.1 | 2083.2 | 294.2 | 113.1 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និង ផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 14.4 | 22.8 | 21.7 | 20.2 | 45.3 | 17.6 | 52.1 | 39.7 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 88.9 | 33.2 | 117.5 | 57.6 | 40.9 | 55.1 | 65.6 | 60.0 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 35.9 | 88.8 | 40.6 | 94.3 | 51.2 | 68.2 | 369.3 | 252.2 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 139.2 | 144.7 | 179.7 | 172.2 | 137.3 | 140.9 | 486.9 | 351.9 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 78.0 | 3.9 | 24.2 | -4.2 | -1.4 | 2.6 | 245.6 | -27.7 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 106.5 | 76.0 | 88.2 | 120.2 | -1.4 | -2.6 | 170.9 | 104.4 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 1708.1 | 2108.1 | 2352.8 | 2799.9 | 707.8 | 705.0 | 890.8 | 793.4 | 803.1 | 539.6 | 928.7 | 728.6 |
| រួមមាន: សំលៀកបំពាក់ | 1628.4 | 2027 | 2253.3 | 2698.9 | 677.5 | 688.2 | 846.1 | 727.1 | 773.4 | 463.8 | 868.8 | 678.8 |
| កៅស៊ូ | 35.1 | 38.3 | 36.7 | 41.4 | 8.4 | 6.9 | 11.7 | 14.6 | 7.0 | 11.0 | 12.9 | 5.2 |
| ឈើ | 10.2 | 11.1 | 10.3 | 8.6 | 2.1 | 2.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ត្រី | 2.8 | 10.6 | 10.1 | 5.9 | 0.7 | 0.4 | 1.2 | 0.9 | 0.7 | 0.3 | 0.6 | 0.6 |
| ការនាំចូលសរុប | 1824.9 | 2149.0 | 2513.0 | 3057.0 | 790.9 | 911.6 | 924.5 | 982.7 | 983.8 | 1178.5 | 1027.1 | 916.3 |
| រួមមាន: ផលិតផលប្រេងកាត | 191.6 | 187.0 | 184.8 | 238.5 | 66.5 | 68.5 | 71.0 | 58.9 | 60.0 | 64.6 | 68.3 | 62.9 |
| សំភារៈសំណង់ | 80.8 | 95.3 | 134.7 | 154.4 | 44.1 | 31.6 | 34.9 | 32.5 | 39.7 | 40.7 | 35.6 | 29.9 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245.0 | 2731.0 | 699.2 | 807.5 | 818.6 | 891.3 | 884.1 | 1073.2 | 923.2 | 823.5 |
| ជញ្ជីងពាណិជ្ជកម្ម | -116.8 | -40.9 | -160.1 | -257.1 | -83.1 | -208.1 | -30.7 | -189.3 | -180.7 | -638.9 | -98.4 | -187.7 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | -5.4 | 1.6 | 22.9 | -14.1 | 6.4 | -40.0 | 87.3 | -21.9 |
| ការនាំចេញសរុប | - | - | - | - | -3.9 | 0.4 | 26.4 | -10.9 | 1.2 | -32.8 | 72.1 | -21.5 |
| ការនាំចូលសរុប | - | - | - | - | -2.0 | 15.3 | 1.4 | 6.3 | 0.1 | 19.8 | -12.8 | -10.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | -54.1 | -64.9 | 291.4 | 19.8 | 19.2 | 8.8 | 8.2 | 1.6 | 14.2 | -32.6 | 2.7 | -6.6 |
| ការនាំចេញសរុប | 17.5 | 23.4 | 11.6 | 19.0 | 17.3 | 8.0 | 10.3 | 7.7 | 13.5 | -23.5 | 4.3 | -8.2 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | 21.6 | 14.5 | 17.6 | 17.9 | 21.7 | 24.4 | 29.3 | 11.1 | -6.8 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by National Bank of Cambodia*

តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 373.6 | 275.6 | 278.5 | 368.8 | 402.0 | 262.0 | 259.2 | 316.2 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 177.2 | 148.9 | 153.3 | 239.2 | 242.2 | 192.0 | 186.3 | 261.4 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 550.8 | 424.5 | 431.8 | 608.0 | 644.2 | 454.0 | 445.5 | 577.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 6.7 | -22.9 | 1.7 | 40.8 | 6.0 | -29.5 | -1.9 | 29.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 20.4 | 19.2 | 16.5 | 17.8 | 17.0 | 6.9 | 3.2 | -5.0 |

*Source: Ministry of Tourism*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០៣-០៨ (ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 Q1 | Q2 | Q3 | Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1764 | 2126 | 2625 | 3259.2 | 824.9 | 1016.8 | 1031.4 | 1146.1 | 1194.1 | 1463.6 | 1297.0 | 1335.3 |
| ចំណូលចរន្ត | 1733 | 2107 | 2474 | 2881.8 | 824.9 | 1012.4 | 1031.4 | 1141.6 | 1189.4 | 1447.0 | 1288.3 | 1286.0 |
| ចំណូលពន្ធ | 1220 | 1577 | 1911 | 2270.9 | 699.9 | 887.7 | 844.6 | 965.2 | 978.0 | 1255.0 | 1071.2 | 1105.7 |
| ពន្ធក្នុងស្រុក | - | - | - | - | 487.9 | 642.1 | 584.8 | 661.8 | 719.9 | 955.5 | 776.7 | 796.3 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 212.1 | 245.6 | 259.8 | 303.5 | 258.1 | 299.5 | 294.5 | 309.4 |
| ចំណូលមិនមែនពន្ធ | 513 | 530 | 563 | 610.9 | 125.0 | 124.7 | 186.9 | 176.4 | 211.4 | 192.1 | 217.1 | 180.2 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 27.9 | 15.5 | 14.8 | 13.6 | 2.9 | 53.9 | 11.0 | 10.2 |
| លក់ទំនិញ និងសេវា | - | - | - | - | 88.8 | 93.0 | 100.1 | 124.3 | 118.9 | 96.3 | 99.7 | 109.8 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 8.3 | 16.2 | 72.0 | 38.5 | 89.6 | 41.9 | 106.4 | 60.3 |
| ចំណូលជាមូលធន | 31 | 19 | 152 | 377.4 | 0.0 | 4.5 | 0.0 | 4.5 | 4.8 | 16.5 | 8.7 | 49.3 |
| ចំណាយសរុប | 2757 | 2932 | 3295 | 4174.7 | 923.9 | 1098.7 | 1126.1 | 1689.7 | 1059.1 | 1744.7 | 1662.8 | 1831.2 |
| ចំណាយជាមូលធន | 1171 | 1163 | 1328 | 1638.1 | 367.1 | 408.1 | 355.1 | 807.4 | 411.0 | 648.2 | 641.2 | 874.0 |
| ចំណាយចរន្ត | 1586 | 1769 | 1967 | 2536.8 | 556.8 | 681.6 | 771.0 | 882.3 | 648.1 | 1096.5 | 918.0 | 1146.4 |
| បៀវត្សរ៍ | 615 | 640 | 711 | 822.0 | 199.7 | 242.7 | 253.4 | 362.6 | 250.7 | 367.0 | 363.6 | 415.7 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 61.9 | 184.0 | 115.0 | 194.2 | 104.3 | 325.7 | 111.9 | 385.2 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 295.2 | 254.9 | 402.6 | 325.5 | 193.1 | 403.8 | 442.6 | 345.4 |
| សមតុល្យជាទូទៅ | -993 | -806 | -706 | -915.6 | -99.0 | -81.9 | -78.7 | -543.6 | 135.0 | -281.1 | -365.8 | -495.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886 | 864 | 1127 | 1360.7 | 344.0 | 313.9 | 290.3 | 741.5 | 299.2 | 615.8 | 435.0 | 705.1 |
| ហិរញ្ញប្បទានក្នុងស្រុក | 106 | 148 | -396 | -445.1 | -245.0 | -213.0 | -148.0 | -185.8 | -294.1 | -236.5 | 234.7 | 168.9 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 Q1 | Q2 | Q3 | Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 1.1 | 3.9 | 5.8 | 4.7 | 3.0 | 4.6 | 6.0 | 9.7 | 16.5 | 24.9 | 21.7 | 15.7 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 1.5 | 6.4 | 8.6 | 6.4 | 3.0 | 7.2 | 11.3 | 18.1 | 27.6 | 43.5 | 35.2 | 26.1 |
| - ដឹកជញ្ជូន | 4.9 | 9.7 | 11.4 | 9.1 | 5.2 | 5.0 | 3.1 | 9.9 | 18.8 | 25.3 | 25.4 | 8.0 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3973.3 | 4016.3 | 4119.7 | 4119.0 | 4063.0 | 4075.4 | 4082.3 | 4030.1 | 3995.3 | 4030.2 | 4117.5 | 4089.8 |
| រៀលក្នុង ១ បាតថៃ | 95.8 | 99.9 | 102.6 | 108.7 | 113.7 | 118.0 | 130.0 | 129.3 | 129.1 | 125.4 | 121.9 | 117.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.5 | 25.8 | 25.1 | 24.6 | 24.7 | 25.3 | 25.2 | 25.2 | 24.9 | 24.8 | 24.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 41.4 | 46.3 | 54.0 | 70.6 | 77.7 | 79.8 | 80.8 | 94.4 | 111.6 | 107.7 | 106.0 | 98.2 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1508 | 2088 | 2633 | 3140 | 3067 | 3100 | 3203 | 3679 | 3982 | 4975 | 5495 | 3768.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 2150 | 2833 | 3442 | 4004 | 3750 | 3900 | 4002 | 4368 | 4580 | 5171 | 5391 | 3861.3 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-០៨ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 Q1 | Q2 | Q3 | Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4027 | 4797 | 5475 | 7224 | 8056 | 9048 | 9768 | 10,735 | 10,911 | 11,353 | 10,809 | 10,345 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698 | -467 | -450 | -282 | -263 | -172 | 140 | 576 | 1136 | 1345 | 1748 | 1513.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128 | -209 | -421 | -953 | -1176 | -1403 | -1547 | -1816 | -2400 | -2678 | -2653 | -2987 |
| ឥណទានដល់ផ្នែកឯកជន | 1337 | 1817 | 2394 | 3630 | 4066 | 4537 | 5376 | 6386 | 8050 | 9206 | 9781 | 9894 |
| រូបិយវត្ថុទូទៅ M2 | 3329 | 4330 | 5025 | 6942 | 7793 | 8876 | 9908 | 11,311 | 12,047 | 12,698 | 12,557 | 11,858 |
| រូបិយវត្ថុ M1 | 937 | 1153 | 1323 | 1658 | 1794 | 1748 | 1750 | 2052 | 2389 | 2467 | 2335 | 2399 |
| រូបិយវត្ថុផ្សេងៗ | 2392 | 3177 | 3702 | 5285 | 5999 | 7128 | 8158 | 9259 | 9658 | 10231 | 10,223 | 9459 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 36.5 | 46.8 | 53.4 | 62.9 | 54.5 | 43.1 | 26.7 | 4.8 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 23.9 | 15.7 | 12.0 | 23.8 | 33.2 | 41.1 | 33.4 | 16.9 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 40.7 | 57.3 | 66.5 | 75.2 | 61.0 | 43.5 | 25.3 | 2.2 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 វិច្ឆិកា | 2003 | 2004 | 2005 | 2006 វិច្ឆិកា | 2007 សីហា | វិច្ឆិកា | 2008 វិច្ឆិកា | 2009 កុម្ភៈ | 2007 វិច្ឆិកា | 2008 វិច្ឆិកា | 2009 កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 7126 | 9393 | 12,628 | 8366 | 27 | 34 | -34 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 7704 | 8852 | 9004 | 10,270 | 26 | 2 | 14 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 9116 | 8303 | 9893 | 7464 | 36 | 19 | -25 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 6038 | 5560 | 4651 | 5068 | 42 | -16 | 9 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4193 | 4508 | 4327 | 4198 | 0 | -4 | -3 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4561 | 4790 | 7541 | 6256 | 3 | 57 | -17 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 9033 | 8207 | 7582 | 7617 | -8 | -8 | 1 |
| អ្នករត់ម៉ូតូឌុប | 8610 | 10,092 | 9204 | 8201 | 8386 | 8979 | 11,525 | 15,658 | 11,422 | 37 | 36 | -27 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5901 | 7550 | 8779 | 5995 | 43 | 16 | -32 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 11,723 | 10,956 | 12,710 | 11,539 | 7 | 16 | -9 |

* *Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*